## បទបង្ហាញស្ដីពី

# ការបង្កើតក្រុមកសិករសិក្សាខ្នាតតូច

# Smallholder Learning Group (SLG)

## សម្រាប់កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នៅនឹងការប្រែប្រួលអាកាសធាតុ ( ASPIRE )

**បទបង្ហាញដោយ ក្រុមការងារកម្មវិធី ASPIRE មន្ទីរកសិកម្មខេត្តពោធិ៍សាត់**

ពោធិ៍សាត់ ថ្ងៃទី ២០-២២ ខែ មេសា ឆ្នាំ២០១៦

# ក. ការចុះរៀបចំប្រជុំផ្សព្វផ្សាយថ្នាក់ភូមិ

1. គោលបំណង និងគោលដៅនៃការបង្កើតក្រុម
2. អត្តន័យក្រុម
3. គុណសម្បត្តិ និងគុណវិបត្តិក្រុម
4. កំណត់ចំណាត់ថ្នាក់ធនធានក្នុងភូមិ
5. លក្ខណៈវិនិច្ឆ័យអ្នកចូលរួម (កំណត់អ្នកចូលរួម ២៥នាក់)

## ១. គោលបំណង និងគោលដៅ

ការចងក្រងក្រុមកសិករសិក្សាខ្នាតតូច នៅតាមភូមិ ឃុំគោលដៅ ដើម្បីជំរុញការយល់ដឹងនិងបង្កើនសមត្ថភាពរបស់ក្រុមកសិករពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុលើផលិតកម្មកសិកម្មនិងជីវភាពរស់នៅ និងដំណោះស្រាយ និងតម្រូវការបច្ចេកទេសកសិកម្ម និងជម្រើសនានាដើម្បីបន្សាំ និងបង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ។

**គោលបំណង** បង្កើនប្រសិទ្ធភាពនៃការចូលរួមរបស់កសិករបង្ករភាពងាយស្រួលក្នុងការផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ដើម្បីបង្កើនប្រាក់ចំណូលគ្រួសារតាមរយៈ សិក្សាខ្នាតតូច ការផ្លាស់ប្តូរបទពិសោធន៍ និងបង្កភាពងាយស្រួលក្នុងការទំនាក់ទំនង។

# ១. គោលបំណង និងគោលដៅ (ត)

ឯកសារការចងក្រងក្រុមកសិករសិក្សាខ្នាតតូចមានគោលដៅលម្អិតដូចខាងក្រោម៖

- ដើម្បីជួយណែនាំដល់មន្ត្រីផ្សព្វផ្សាយកសិកម្មក្នុងការបង្កើតក្រុមកសិករសិក្សាខ្នាតតូច
- បង្កើតនូវក្រុមកសិករសិក្សាខ្នាតតូចដ៏រឹងមាំដែលពួកគេអាចយល់ដឹងអំពីរបៀបក្នុងការគ្រប់គ្រងដោយខ្លួនឯងនៅក្នុងតំបន់គោលដៅរបស់កម្មវិធី
- កំណត់តម្រូវការជម្រើសបច្ចេកទេស និងបច្ចេកវិទ្យា និងការកសាងសមត្ថភាពរបស់កសិករ ដើម្បីបន្សាំ និងពង្រឹកភាពធន់នឹងការប្រែប្រួលអាកាសធាតុនៅតាមភូមិ ឃុំគោលដៅ
- ដើម្បីជួយពង្រឹងអំណាចក្រុមកសិករសិក្សាខ្នាតតូចនិងមាននិរន្តរភាពក្នុងការបង្កើនជីវភាពស់នៅ។

## ២. អត្ថន័យរបស់ក្រុម

- កសិករមានគំនិត និងចំណាប់អារម្មណ៍ដូចគ្នាឬប្រហាក់ប្រហែលគ្នា
- កសិករមានគោលបំណងរួម
- កសិករស្ម័គ្រចិត្តរួមសហការជាមួយគ្នា
- កសិករមានភាពស្មោះត្រង់ តស៊ូ និងទទួលខុសត្រូវជាមួយគ្នា
- កសិករបានត្រៀមខ្លួនរួចជាស្រេចក្នុងការរៀបចំដោយខ្លួនឯងនូវកិច្ចប្រជុំការធ្វើផែនការ សកម្មភាពរួមគ្នា
- កសិករបានត្រៀមខ្លួនក្នុងការជ្រើសរើស &ចូលរួមក្នុងគណៈកម្មាធិការគ្រប់គ្រងក្រុម
- កសិករស្ម័គ្រចិត្តចូលរួមបង្កើត និងគោរពតាមលក្ខន្តិកៈ ឬបទបញ្ញាផ្ទៃក្នុងដែលខ្លួនបានបង្កើត
- កសិករស្ម័គ្រចិត្តចូលរួម និងទទួលផលប្រយោជន៍ជាមួយគ្នា
- កសិករស្ម័គ្រចិត្តចូលរួមបង់ប្រាក់សមាជិកភាព
- កសិករស្ម័គ្រចិត្តចូលរួមគ្នាធ្វើការសន្សំប្រាក់

# ៣. គុណសម្បត្តិនិងគុណវិបត្តិនៃក្រុមកសិករ

## គុណសម្បត្តិនៃក្រុមកសិកររួមមាន

- សមាជិកអាចទទួលបានផលចំណេញច្រើនជាងមុនតាមរយៈការធ្វើការងារជាក្រុមជាជាងការបែកខ្ញែកគ្នា ដូចជាការទិញសម្ភារៈកសិកម្ម និង លក់ កសិផល រួមគ្នា
- សមាជិកអាចទទួល និងចែករំលែកពីគ្នាទៅវិញទៅមកនូវ ព័ត៌មាន បទពិសោធន៍ និងចំណេះដឹង
- សមាជិកអាចជួយគ្នាទៅវិញទៅមក (ការប្រវាស់ដៃគ្នា)
- ធនធានត្រូវបានការពារ និងប្រើប្រាស់ជាផលប្រយោជន៍របស់ក្រុម ប្រសើរជាងការដែលត្រូវបានធ្លាក់ទៅលើអ្នកមាន ឬអ្នកមានឥទ្ធិពលមួយចំនួនតូច
- មានប្រសិទ្ធភាពក្នុងការទាក់ទាញចំណាប់អារម្មណ៍របស់អ្នកផ្តល់សេវាកម្មគាំទ្រ ដូចជាស្ថាប័នផ្តល់ឥណទាន និង ការបណ្តុះបណ្តាលជាដើម...
- តំណាងកសិករអាចមានឥទ្ធិពលកាន់តែខ្លាំងក្នុងការបញ្ចេញយោបល់ជាសម្លេងតែមួយ
- សមាជិកសំខាន់ៗទាំងអស់អាចទទួលបានចំណេះដឹងក្នុងការដឹកនាំ
- អត្តសញ្ញាណខាងវប្បធម៌ និងសកម្មភាពរបស់ពួកគាត់ត្រូវបានគេស្គាល់ និងរឹងមាំជាងមុន
- ទំនាក់ទំនងនៅក្នុងសង្គមនឹងធ្វើឱ្យប្រសើរឡើងនូវបណ្តាញមុខរបររបស់សមាជិកក្រុម

# ៣. គុណសម្បត្តិនិងគុណវិបត្តិនៃក្រុមកសិករ (ត)

## គុណវិបត្តិនៃក្រុមកសិកររួមមាន

- រាល់ការធ្វើសេចក្តីសម្រេចនៅក្នុងក្រុមត្រូវចំណាយពេលយូរ
- ការបែងចែកតួនាទី និងការទទួលខុសត្រូវអាចមានការលំបាកច្រើនៈ ដូចជាសមត្ថភាព ចំណេះដឹង និងបទពិសោធន៍នៅមានកម្រិត
- សមាជិកក្រុមត្រូវតែចូលរួមធ្វើការងារ និងទទួលខុសត្រូវទាំងអស់គ្នា គឺមិនមាននរណាម្នាក់ដែល រួចខ្លួននោះទេ (អាចមានករណីសមាជិកខ្លះក្លាយជាអ្នក "ជិះសេះលែងដៃ" ដែលចូលរួមចំណែក ក្នុងក្រុមតិចតួច ប៉ុន្តែចាំយកផលប្រយោជន៍ស្មើអ្នកដទៃ)
- អាចបង្កឱ្យមានបញ្ហានៅពេលបែងចែកផលប្រយោជន៍ដោយយោងទៅតាមការបំពេញការងារ&ការចូលរួម
- អាចមានទុនមិនគ្រប់គ្រាន់សម្រាប់ធានាមុខរបររបស់ក្រុម

**ដំណោះស្រាយៈ**

- ទាមទារឱ្យមានលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងដែលមានប្រសិទ្ធភាពសម្រាប់អនុវត្ត
- ត្រូវបែងចែកការទទួលខុសត្រូវ និងកំណត់តួនាទីឱ្យបានសមស្របទៅតាមចំណេះដឹង សមត្ថភាព និងបទពិសោធន៍
- ត្រូវមានវិធានការដាក់ពិន័យចំពោះអ្នកដែលមិនបានបំពេញតួនាទីជាសមាជិករបស់ក្រុម
- ត្រូវមានរូបមន្តច្បាស់លាស់ និងសាមញ្ញសម្រាប់ធ្វើការបែងចែកផលប្រយោជន៍ដល់សមាជិកក្រុម

# ៤.ការកំណត់ចំណាត់ថ្នាក់ធនធាន

ឧទាហរណ៍

| គ្រួសាបង្គួរ ( ...........គ្រួសារ ) | គ្រួសារមធ្យម ( ...........គ្រួសារ ) | គ្រួសារក្រ ( ...........គ្រួសារ ) | គ្រួសារក្រណាស់ ( ...........គ្រួសារ ) |
|---|---|---|---|
| ▪ ប្រភេទផ្ទះ................<br>▪ ម៉ូតូ, ម៉ាញ៉េ, TV, VCD, .......<br>▪ ម៉ាស៊ីនបោក និងគោយន្ត<br>▪ ស្បៀងហូបគ្រប់គ្រាន់&សល់លក់<br>▪ ម៉ាស៊ីនបូមទឹក ត្រាក់ទ័រ<br>▪ ឡាន និងសម្ភារៈគ្រប់គ្រាន់<br>▪ ជួលកម្លាំងពលកម្មធ្វើស្រែ<br>▪ ផ្តល់ប្រាក់ឱ្យគេខ្ចី និងចងការ<br>▪ គោ ក្របី .........ក្បាល<br>▪ មានដីស្រែ.......ហិកតា<br>▪ ដីចំការ...........ហិកតា<br>▪ ដីលំនៅដ្ឋាន.....ហិកតា | | | |

បញ្ជីរឈ្មោះកសិករក្នុងភូមិ

# ៥. លក្ខណៈវិនិច្ឆ័យក្នុងការចូលជាសមាជិកក្រុមសិក្សាខ្នាតតូច (SLG)

- កសិករមានទីលំនៅជាក់លាក់ក្នុងភូមិ
- មិនចំណាកស្រុក
- កសិករមានការស្ម័គ្រចិត្តចូលរួម
- មានផ្ទៃដីសម្រាប់ដាំដុះ ចិញ្ចឹមសត្វ
- មានកម្លាំងពលកម្មអាចចូលរួមសកម្មភាពក្នុងក្រុមបាន
- មានពេលវេលាគ្រប់គ្រាន់ក្នុងការចូលរួម
- សមាជិកក្រុម១នាក់ ក្នុង១គ្រួសារ
- មានចិត្តទូលំទូលាយក្នុងការចែករំលែកបទពិសោធន៍
- ត្រូវមានស្ត្រីចូលរួមយ៉ាងតិច ៣០%
- មិនប្រកាន់ពូជសាសន៍ នយោបាយ
- កសិករដែលងាយរងគ្រោះដោយបម្រែបម្រួលអាកាសធាតុ( តំបន់រាំងស្ងួត ទឹកជំនន់ )
- មានកសិករក្រីក្រចូលរួមដែរ

# ខ. ចុះរៀបចំបង្កើតក្រុម

- វំលឹកឡើងវិញអំពីការប្រជុំលើកមុន
  - អញ្ជើញអ្នកចូលរួមទាំង២៥នាក់
- ជ្រើសរើសថ្នាក់ដឹកនាំក្រុម (ប្រធាន អនុប្រធាន លេខាធិការ)
- តួនាទី និងភារកិច្ចថ្នាក់ដឹកនាំក្រុម
- ចុះពិនិត្យដល់ផ្ទះកសិករជាក់ស្តែង

# ការជ្រើសរើស និងបោះឆ្នោតគណៈកម្មាធិការគ្រប់គ្រងក្រុម

- ❖ បំផុសគំនិតឱ្យកសិកររកនឹកនូវ អត្ថន័យ នៃគណៈកម្មាធិការគ្រប់គ្រងក្រុមកសិករ និងសមាជិក ហេតុអ្វីបានជាក្រុមត្រូវការគណៈកម្មាធិការគ្រប់គ្រង ?
- ❖ លក្ខណៈវិនិច្ឆ័យសម្រាប់បេក្ខភាពគណៈកម្មាធិការគ្រប់គ្រងក្រុម( ប្រធាន អនុប្រធាន លេខាធិការ )
- ❖ ពិភាក្សាអំពីតួនាទី និងភារៈកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងក្រុម
- ❖ ធ្វើការជ្រើសរើសសមាជិកដែលស្ម័គ្រចិត្ត (ឬតាមសំណូមពររបស់សមាជិកក្រុម) ឈរឈ្មោះជា បេក្ខជនដឹកនាំក្រុមកសិករ រួចសរសេរឈ្មោះបេក្ខជនទាំងនោះទៅក្នុងក្រដាសផ្ទាំងធំ
- ❖ បង់លេខតំណាងឱ្យបេក្ខជនម្នាក់ៗ
- ❖ សុំឱ្យកសិករបោះឆ្នោតជ្រើសរើសបុគ្គលម្នាក់ ដោយសរសេរលេខតំណាងបេក្ខជនដែលពួកគាត់ចង់បោះឆ្នោតជូននៅក្នុងក្រដាសតូចមួយ រួចប្រគល់ក្រដាសនោះដោយមិនដាក់ឈ្មោះឱ្យទៅមន្ត្រីផ្សព្វផ្សាយ ឬអ្នកសម្របសម្រួល
- ❖ ប្រកាសលេខដែលមាននៅលើក្រដាសផ្ទាំងធំ និងពិន្ទុសរុប
- ❖ រៀបចំបោះឆ្នោតដូចគ្នាសម្រាប់ជ្រើសរើសអនុប្រធានលេខាធិការនិងហិរញ្ញឹក( ម្តងមួយៗ )។

# តួនាទីនិងភារៈកិច្ច ប្រធានក្រុម អនុប្រធាន និង លេខាធិការ

❖ **ប្រធានក្រុម**

- គ្រប់គ្រងនិងដឹកនាំសមាជិកក្រុមរាល់សកម្មភាពការងារ
- ទំនាក់ទំនងជាមួយអ្នកសម្របសម្រួល/ដៃគូអភិវឌ្ឍនានា
- ដោះស្រាយបញ្ហាដែលកើតក្នុងក្រុម
- ដឹកនាំរៀបចំធ្វើផែនការ ធ្វើការសម្រេចចិត្ត

# តួនាទីនិងភារៈកិច្ច ប្រធានក្រុម អនុប្រធាន និង លេខាធិការ

- **អនុប្រធានក្រុម**
  - ជំនួសដឹកនាំការងារពេលប្រធានអវត្តមាន
  - ចូលរួមគ្រប់សកម្មភាពការងារចាត់តាំងរបស់ប្រធាន
  - ចូលរួមប្រជុំផ្សេងៗនិងរាយការណ៍ជូនប្រធាន
  - ចូលរួមរៀបចំធ្វើផែនការ
  - ជំនួយការប្រធាន

# តួនាទីនិងភារៈកិច្ច ប្រធានក្រុម អនុប្រធាន និង លេខាធិការ

❖ **លេខាធិការ**

- កត់ត្រារាល់សកម្មភាពដែលក្រុមSLGធ្វើ
- រៀបចំឯកសារ(ទុកដាក់)
- ធ្វើរបាយការណ៏អោយបានទៀងទាត់តាមកំណត់របស់ក្រុម
- ចូលរួមក្រុមសកម្មភាពតាមការចាត់តាំងរបស់ប្រធាន
- រាយការណ៏ជូនប្រធាន
- ជាអ្នកផ្តល់ព័តមានអោយសមាជិកក្រុម
- គ្រប់គ្រងចំណូលចំណាយរបស់ក្រុម (ប្រសិនបើមាន)

# ចុះពិនិត្យដល់ផ្ទះសមាជិកក្រុម SLG

ដើម្បីថតរូបផ្ទះសមាជិកក្រុម មុនពេលកម្មវិធីចាប់ផ្តើមអនុវត្ត

# សូមអរគុណ

## ចំពោះការយកចិត្តទុកដាក់ស្តាប់របស់អស់លោក លោកស្រី